Notice
Can't identify browser version. Agent: Mozilla/5.0 (Macintosh; Intel Mac OS X) AppleWebKit/534.34 (KHTML, like Gecko) Qt/4.8.7 Safari/534.34

## បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

សំរាប់ព័ត៌មានលំអិត សូមចុចមកលេខ 115

**NEW COVID-19 Updated 25-03-2020**

រហូតម៉ោង ១៩ះ៣០ នាទីយប់ ថ្ងៃទី ២៥ មីនា ២០២០ រកឃើញករណីថ្មីអ្នកវិជ្ជមាន COVID-19 ០២នាក់ ជាអ្នកទេសចរជនជាតិបារាំង និង ០៣នាក់ទៀត ជាជនជាតិខ្មែរ ហើយអ្នកជាសះស្បើយមានចំនួន ០៩នាក់។

សរុបអ្នកឆ្លងទាំងអស់ ៩៦នាក់ ក្នុងនោះ ១០ នាក់បានជាសះស្បើយ។

សំរាប់ទូរលេខលំអិតៈ https://covid19-map.cdcmoh.gov.kh/



Read more: បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

## សារអប់រំទាក់ទងនឹងកូវី ១៩

***Date: 23/March/2020***

ការកាត់បន្ថយហានិភ័យពីការឆ្លងកូវីត១៩ (COVID19) ដោយវិធីដ៏សាមញ្ញដូចខាងក្រោមៈ

ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥





## សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដែលបានឧបត្ថម្ភថវិកា ដល់មន្ត្រីទទួលបន្ទុក ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ និងមន្ត្រីនាយកដ្ឋាន ប្រយុទ្ធនឹងជំងឺឆ្លង

***Date: 23/March/2020***

យើងខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដូចមានរាយនាមខាងក្រោម ដែលបានឧបត្ថម្ភថវិកា
ដល់មន្ត្រីទទួលបន្ទុកទូរស័ព្ទទាន់ហេតុការណ៍ ១១៥ (២៤ម៉ោង/៧ថ្ងៃ) និងមន្ត្រីនាយកដ្ឋានដើម្បីលើកទឹកចិត្ត និងរួមចំណែកក្នុងការប្រយុទ្ធ និងទប់ស្កាត់ជំងឺកូវីដ១៩
សូមប្រសិទ្ធពរបវរសួស្តីមហាប្រសើរ ជូនដល់លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។
យើងខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានឧបត្ថម្ភ និងលើកទឹកចិត្តដល់យើងខ្ញុំផងដែរ។

ថ្ងៃ ចន្ទ ១៥រោច ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០





# នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយៈពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល

***Date: 22/March/2020***

សូមបងប្អូនដែលទើបធ្វើដំណើរ ត្រលប់ពីបរទេសទាំងអស់ សូមមេត្តាដាក់ខ្លួនឯង ឲ្យនៅដាច់ដោយឡែក ចំនួន១៤ថ្ងៃ និងតាមដានសុខភាព បើមានចេញរោគសញ្ញា សូមពិគ្រោះជំងឺជាមួយទូរស័ព្ទលេខ ១១៥ ។ សូមអានសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ។



# មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ចាតចេញមកក្រៅ តាមរយៈការក្អកឬកណ្តាស់

***Updated: 19/March/2020***








មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ចាតចេញមកក្រៅតាមរយៈក្អកឬកណ្តាស (មិនមែនហោះហើរក្នុងខ្យល់ទេ) ។ ត្រូវចងចាំថា ដំណក់ទឹកតូចៗអ្នកជំងឺដល់ទីណា មេរោគនឹងទៅដល់ទីនោះ ។អ្នកវិទ្យាសាស្ត្ររកឃើញថា ចំងាយខ្ចាតចេញពីមុខមនុស្សយើងចំងាយបាន ៣ហ្វីត បើគិតពីរង្វាស់ម៉ែត្រគឺ ៩០សង់ទីម៉ែត្រ ។ ដូច្នេះបើយើងនៅឆ្ងាយពីអ្នកជំងឺលើសពី១ម៉ែត្រ យើងនឹងគេចផុតពីដំណក់ទឹកតូចៗទាំងនោះ ។
ពេលអ្នកជំងឺក្អកឬកណ្តាសម្តងៗ បណ្តាលឱ្យខ្ចាតទៅលើផ្ទៃផ្សេងៗ ដូចជាលើតុ លើជញ្ជាំង លើបង្កាន់ដៃ ។ ល។ និងដៃរបស់គាត់ក្រោយញីច្រមុះប្រលាក់សំបោរ ប៉ះដៃទ្វារប៉ះជញ្ជាំងប៉ះបង្កាន់ដៃ ដែលអ្នកជាប៉ះផ្ទៃទាំងនោះបណ្តាលឱ្យឆ្លងពេលយើងប៉ះមុខនិងច្រមុះ ។អ្នកវិទ្យាសាស្ត្ររកឃើញថា ក្នុងមួយថ្ងៃមនុស្សយើងប៉ះមុខជាមធ្យម ៦០ដង ។ ហេតុដូច្នេះ តំរូវឱ្យអ្នកជំងឺត្រូវពាក់ម៉ាស់ដើម្បីកុំឱ្យខ្ចាតចេញមកក្រៅ
និងទាំងអ្នកឈឺនិងអ្នកជាត្រូវតែឧស្សាហ៍លាងដៃជាមួយសាប៊ូ អាល់កុល ជេល ជាដើម ។ ចំពោះអ្នកជាពុំចាំបាច់ពាក់ម៉ាស់ទេ គឺយើងពាក់ម៉ាស់នៅពេលចាំបាច់ដូចជា កន្លែងប្រមូលផ្តុំ សួរសុខទុកអ្នកជំងឺ និងក្រុមគ្រូពេទ្យ ហើយគ្រវាត់ម៉ាស់ក្នុងធុងសំរាមភ្លាមក្រោយប្រើប្រាស់ ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

- លេខ ១១៥ មានអ្នកទូរសំព្ទចូលរហូតដល់ ជាង៩៣មុឺននាក់ គិតចាប់ពីពេលរកឃើញកូវិត១៩ ករណីទី១មក
- A passenger on flight PG933 from Bangkok to Phnom Penh (9 MARCH 2020) has tested positive for COVID19
- របៀបដោះស្រាយ នៅពេលយើងមានបញ្ហាផុញថប់ តានតឹង ក្នុងកំឡុងពេលមានការរកឃើញ ករណីជំងឺកូវិត១៩ ជាបន្តបន្ទាប់ ក្នុងប្រទេសយើង
- ក្រសួងសុខាភិបាលកម្ពុជា ដាក់បំរាមផ្អាកមិនអោយជនបរទេស ដែលមកពីប្រទេស អ៊ីតាលី អាល្លឺម៉ង់ អេស្ប៉ាញ បារាំង និង អាមេរិក ចូលមកក្នុងប្រទេសកម្ពុជា



Press Release
- Avian Influenza
- SARS
- Severe Watery Diarrhea
- Swine Influenza
- Other Disease
- MERS

Bulletins
- Year 9 (2012)
- Year 8 (2011)
- Year 7 (2010)
- Year 6 (2009)
- Monthly respiratory buttletin
  - Year 2014
  - Year 2015
  - Year 2016
  - Year 2017

IEC material and documents
- Posters

- Booklets
- Radio Spot
- TV Spots
- Leaflet
- National Guideline, Policy, and Strategy

Applied epidemiology training

- Course detail
- Team and advisory board
- First cohort (2011)
- Second cohort (2012)
- Documents and forms

Collaborative Projects with Hopital Service

## Latest Articles

- បច្ចុប្បន្នភាពនៃជំងឺកូវីដថ្មី COVID-19 នៅប្រទេសកម្ពុជា
- សារអប់រំទាក់ទងនឹងកូវី ១៩
- COVID-19 Documents Management
- សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដែលបានឧបត្ថម្ភថវិកា ដល់មន្ត្រីទទួលបន្ទុក ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ និងមន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
- នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយះពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះដាលក្ខណៈបុគ្គល

## Login Form

User Name

Password

Remember Me

Log in

Forgot your username?
Forgot your password?

## Visitors Counter

| | |
|---|---|
| Today | 3477 |
| Yesterday | 3599 |
| This week | 10939 |
| This month | 47619 |
| Total | 980012 |

Powered by CoalaWeb

© 2020 CDC Department Website